**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៥៩/១៦ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង

យោងសេចក្តីជូនដំណឹងរបស់ក្រសួងធនធានទឹក និងឧតុនិយម ស្តីពីស្ថានភាពអាកាសធាតុក្តៅហួតហែងខ្លាំងជាមួយបរិមាណទឹកភ្លៀងកក់ខែមានចំនួនតិចតួចនារដូវប្រាំងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ជាពិសេសសហគ្រាស គ្រឹះស្ថានកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងទាំងអស់ឱ្យបានជ្រាបថា បាតុភូតអាកាសធាតុខាងលើ នឹងធ្វើឱ្យកំដៅក្នុងរោងចក្រកើនឡើង ដែលអាចបង្កឱ្យកម្មករនិយោជិតខ្វះជាតិទឹក ឬងាយនឹងធ្លាក់ខ្លួនឈឺ ។

ដើម្បីបញ្ចៀសបាននូវហានិភ័យខាងលើនេះ និងដើម្បីបង្ការការកើតមានការដួលសន្លប់ជាយថាហេតុ និងដើម្បីការពារការខាតបង់របស់សហគ្រាស គ្រឹះស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ អនុវត្តឱ្យបានម៉ត់ចត់នូវវិធានការដូចខាងក្រោមៈ

១- ត្រូវមើលថែទាំ និងត្រួតពិនិត្យជាប្រចាំ និងបើកឱ្យដំណើរការប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់នៅតាមអគារផលិតកម្មទាំងអស់ ឱ្យបានយ៉ាងហោចមួយម៉ោងមុនពេលអនុញ្ញាតឱ្យកម្មករនិយោជិតចូលបម្រើការងារ ស្របតាមប្រកាសលេខ១២៥ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ

២- ត្រូវដាក់ឱ្យមានឧបករណ៍វាស់ស្ទង់កំដៅ (សីតុណ្ហមាត្រ) នៅកន្លែងធ្វើការ ដើម្បីងាយស្រួលក្នុងតាមដានការវិវត្តនៃកំដៅ

៣- ត្រូវរៀបចំទុកដាក់សម្ភារៈ កុំឱ្យបាំងប្រភពខ្យល់ចេញចូល

៤- ត្រូវបើកបង្អួច ទ្វា ឱ្យបានធំទូលាយ ឬបន្ថែមកង្ហារបញ្ចូលខ្យល់ក្នុងអគារផលិតកម្មនៅពេលមានអាកាសធាតុក្តៅ

៥- ត្រូវរៀបចំឱ្យមានប្រព័ន្ធស្រោចទឹកនៅលើដំបូលអគារផលិតកម្ម ឱ្យបានយ៉ាងហោចពីរដងក្នុងមួយថ្ងៃ ឬបន្ថែមសំណាញ់នៅលើដំបូលអគារផលិតកម្មដើម្បីកាត់បន្ថយកំដៅ

៦- ត្រូវផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិត ស្របតាមប្រកាសលេខ០៥៤ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ

៧- ត្រូវមើលថែទាំ និងត្រួតពិនិត្យជាប្រចាំប្រព័ន្ធបង្ការអគ្គីភ័យ និងសម្ភារៈការពាររួមនៅក្នុងអគារ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ६៩

សហគ្រាស គ្រឹះស្ថានឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងធានាថាប្រព័ន្ធ និងឧបករណ៍ទាំងនោះ អាចដំណើរការបាន ក្នុងពេលមានគ្រោះអាសន្នកើតឡើងព្រមទាំងអនុវត្តតាមការណែនាំរបស់ក្រុមអធិការកិច្ចការងារតែមួយ

៨- ត្រូវរៀបចំឱ្យមានប្លង់សម្រាប់ជម្លៀសខ្លួន សញ្ញាការសុវត្ថិភាពនៅតាមបុស្តិ៍ការងារ និងការអប់រំបណ្តុះបណ្តាលកម្មករនិយោជិត ស្របតាមប្រកាសលេខ ១៧៦ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព

៩- ចំពោះសហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់សារធាតុគីមីងាយឆាបឆេះ ត្រូវរៀបចំឱ្យមានប្រព័ន្ធឆ្លើយតបគ្រោះអាសន្ន និងរក្សាទុកដាក់សារធាតុទាំងនោះឱ្យដាច់ដោយឡែកពីគ្នា និងដាច់ឆ្ងាយពីអគារផលិតកម្ម ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**

- ក្រុមបញ្ជាការដ្ឋានអធិការកិច្ចការងារតែមួយ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានការងារ
- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានពេទ្យការងារ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ